

# កំណាព្យ

## រាត្រីកាល

បទពំនោល

សន្ធ្យានកាល[1]ខិតមកដល់ អាកាសធ្លាក់ខ្យល់
ប្តូរផ្តល់នូវរាត្រីកាល។
ត្រជាក់រុំព័ន្ធកាយា សម្លឹងវេហា
ចិន្តានឹកដល់ស្រីពៅ។
អង្គុយរង់ចាំព្រះចន្ទ ស្រូបក្លិនសុគន្ធ[2]
នៅក្បែរគុម្ពផ្កាម្លិះលា។
ព្រះចន្ទគឺពៅពនិតា[3] វិលតាមសន្យា
ភស្តា[4]ចារក្នុងបេះដូង។
ម្សប់[5]ពេញបូណ៌មីលូកដៃ ស្រវាអោបថ្លៃ
ស្រមៃប្រែជាការពិត។
ក្នុងរាត្រីកាលប្រឌិត រឿងយើងជាទិព្វ
ប្រសិទ្ធពរដោយចិត្តស្នេហ៍។

---

[1] សន្ធ្យាកាល : ពេលថ្ងៃលិច។
[2] សុគន្ធ : គុ. ដែលមានក្លិនក្រអូប។
[3] ពនិតា : ភរិយា។
[4] ភស្តា : ស្វាមី។
[5] ម្សប់ : ន. មួយយប់។